ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥...០៧១...៨២០.សជណ

ថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១

# សេចក្ដីណែនាំ
## លើការអនុវត្តឧបករណ៍ផ្ដល់សន្ទនីយភាពរយៈពេលខ្លី
**(Marginal Lending Facility-MLF)**

យោងសេចក្ដីជូនដំណឹងលេខ ធ៥.០២១.៦៤៩.ស.ជ.ណ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ ស្ដីពីការដាក់ឱ្យអនុវត្តឧបករណ៍ផ្ដល់សន្ទនីយភាពរយៈពេលខ្លី (MLF) ធនាគារជាតិនៃកម្ពុជាសូមជម្រាបជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់អំពីលក្ខខណ្ឌចាំបាច់ និងនីតិវិធីមួយចំនួនក្នុងការស្នើសុំ MLF ដូចតទៅ៖

**I- លក្ខខណ្ឌនៃការស្នើសុំ MLF**

- ចុះកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញជាមួយធនាគារជាតិនៃកម្ពុជា
- ត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ផ្ទៃតប្លង់ធនាគារជាតិនៃកម្ពុជា (NBCP)
- យល់ព្រមលើលក្ខខណ្ឌ និងខចែងនៃប្រតិបត្តិការ MLF
- ត្រូវមានមូលបត្រអាចជួញដូរបាន NCD ជាវត្ថុធានា។

**II- នីតិវិធីក្នុងការស្នើសុំ MLF**

- ការស្នើសុំ MLF ត្រូវធ្វើឡើងតាមប្រព័ន្ធ NBCP
- ការស្នើសុំ MLF គ្រាទី១ (Session 1) ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៩:៣០នាទីព្រឹក គ្រឹះស្ថាននឹងទទួលបានសន្ទនីយភាពនៅម៉ោង ១០:១៥ នាទីព្រឹក
- ការស្នើសុំ MLF គ្រាទី២ (Session 2) ចាប់ពីម៉ោង ៩:៣០ នាទីព្រឹក រហូតដល់ម៉ោង ២:០០ រសៀល គ្រឹះស្ថាននឹងទទួលបានសន្ទនីយភាពនៅម៉ោង ២:៤៥ នាទីរសៀល
- អត្រាការប្រាក់កំណត់ដោយធនាគារជាតិនៃកម្ពុជា
- ទំហំទឹកប្រាក់ដែលអាចស្នើសុំអាស្រ័យលើវត្ថុធានា ដែលគ្រឹះស្ថានប្រើប្រាស់ជាវត្ថុធានា។ គណប្រតិទានរបស់វត្ថុធានា ត្រូវតែមានរយៈពេលវែងជាងគណប្រតិទានរបស់ MLF ដែលស្នើសុំយ៉ាងតិចមួយថ្ងៃនៃថ្ងៃធ្វើការ។ អត្រា Haircut សម្រាប់វត្ថុធានាកំណត់ដោយធនាគារជាតិនៃកម្ពុជា
- MLF អាចផ្ដល់ទៅក្នុងគណនីចរន្ត ឬគណនីទូទាត់តាមការស្នើសុំរបស់គ្រឹះស្ថាន
- លទ្ធផលនៃការស្នើសុំនឹងបង្ហាញជូនគ្រឹះស្ថានតាមប្រព័ន្ធ NBCP។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**III- នីតិវិធីនៃការបន្តឥណប្រតិទានរបស់ MLF**

- គ្រឹះស្ថានអាចស្នើសុំបន្តឥណប្រតិទានរបស់ MLF មួយថ្ងៃម្តង
- ការស្នើសុំបន្តឥណប្រតិទានរបស់ MLF តិចជាង ឬស្មើ ៥ ថ្ងៃនៃថ្ងៃធ្វើការ
- ការស្នើសុំបន្តឥណប្រតិទានរបស់ MLF ត្រូវធ្វើឡើងតាមប្រព័ន្ធ NBCP មុនឥណប្រតិទាន សម្រាប់គ្រាទី១ (Session 1) មុនម៉ោង ៩:៣០ នាទីព្រឹក និងគ្រាទី២ (Session 2) មុនម៉ោង ២:០០ រសៀល។

**IV- ការទូទាត់សង MLF**

- ការប្រាក់ នឹងត្រូវគណនានៅថ្ងៃស្នើសុំ តាមទំហំទឹកប្រាក់ ឥណប្រតិទាន អត្រាការប្រាក់ និងចំនួនថ្ងៃជាក់ស្តែងក្នុងឆ្នាំនីមួយៗ
- ករណីឥណប្រតិទាន ត្រូវចំថ្ងៃឈប់សម្រាក ការប្រាក់នឹងត្រូវបានគណនាតាមចំនួនថ្ងៃជាក់ស្តែង
- ប្រាក់ដើម និងការប្រាក់ នឹងត្រូវទូទាត់ដោយស្វ័យប្រវត្តិចេញពីគណនីចរន្តរបស់គ្រឹះស្ថានតាមគ្រាដែលគ្រឹះស្ថានទទួលបានសន្ទនីយភាព
- ករណីគណនីចរន្តរបស់គ្រឹះស្ថាន គ្មានសមតុល្យគ្រប់គ្រាន់សម្រាប់ការទូទាត់ប្រាក់ដើម និងការប្រាក់តាមពេលវេលាកំណត់ ធនាគារជាតិនៃកម្ពុជានឹងរឹបអូសយកវត្ថុធានាមកទូទាត់ប្រាក់ដើម និងការប្រាក់។ តម្លៃនៃវត្ថុធានា NCD ត្រូវគណនាតាមវិធីសាស្ត្រទិញត្រឡប់វិញ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជ្រាប និងសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមទំនាក់ទំនង៖
-ធនាគារជាតិនៃកម្ពុជា
-អគ្គនាយកដ្ឋានបច្ចេកទេស
-នាយកដ្ឋានប្រតិបត្តិការ
-លេខទូរស័ព្ទ: (៨៥៥-២៣) ៧២៨ ៩៦៣
(៨៥៥-២៣) ៧២២ ២២១ EXT ១០៤៨
-សារអេឡិចត្រូនិក : mlf_info@nbc.org.kh